# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានតំណាងការិយាល័យអង្គការ JICA ប្រចាំកម្ពុជា ដែលទើបចប់អណត្តិ



នៅរសៀលថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Hiroshi Izaki** ប្រធានតំណាងការិយាល័យនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ( JICA) ប្រចាំកម្ពុជា ដើម្បីសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែលលោក ត្រូវបញ្ចប់បេសកកម្មរយៈពេល ០២ ឆ្នាំ ពីរខែ នៅកម្ពុជា ។ ដោយឡែកលោក **Adachi Itsu** ប្រធានតំណាងថ្មី ក៏មានវត្តមានចូលរួមនាឱកាសនោះដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះបេសកកម្មការងារ របស់លោក **Hiroshi Izaki** ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នានានៅកម្ពុជា។ ក្នុងនោះ គម្រោងជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាសំខាន់នោះ គឺគម្រោងអភិវឌ្ឍន៍ទឹកស្អាត និងការរៀបចំគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបង្ហាញនូវជំនឿថាៈតាមរយៈលោកប្រធានតំណាងថ្មី លោកនឹងបន្តខិតខំអនុវត្តគម្រោងនានា ដើម្បីសម្រេចបានជោគជ័យ ជាមួយក្រសួងឧស្សាហកម្ម សិប្បកម្ម ។ ទាក់ទងចំណុចនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើដល់អង្គការ JICA ពិនិត្យលទ្ធភាពជួយក្រសួងបន្តទៀត ទាក់ទងនឹងការរៀបចំគោលនយោបាយលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដែលគម្រោងនេះនឹងបញ្ចប់នៅចុងខែ មេសា ខាងមុខនេះ។ ដោយឡែក ទាក់ទង និងគម្រោងតបណ្តាញទឹកស្អាតរបស់អង្គការ JICA នៅខេត្តសៀមរាប ដែលត្រូវចំណាយទឹកប្រាក់រហូតដល់ ៩៣ លានដុល្លារអាមេរិកនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានចាត់ទុកថាជាគម្រោងដ៏ធំ និងចាយទឹកប្រាក់ច្រើន ដែលឯកឧត្តមស្នើឱ្យអ្នកជំនាញ JICA ពិនិត្យលទ្ធភាពពិនិត្យមើលគម្រោងប្លង់ រឺក៏អាចកែសម្រួលឡើងវិញខ្លះ ដើម្បីឱ្យការចំណាយមានលក្ខណៈទាបជាងបន្តិច ពីព្រោះការចំណាយលើគម្រោងនេះជា ប្រភេទកម្ចីឥណទាន ។ ម៉្យាងការចំណាយថ្លៃដើមខ្ពស់ វានឹងនាំឱ្យមានការលក់ថ្លៃទឹកខ្ពស់ដែរ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់កំរិតជីវភាពប្រជាពលរដ្ឋ និងអតិថិជន ជាអ្នកប្រើប្រាស់ ។

លោក **Hiroshi Izaki** ប្រធានតំណាងការិយាល័យនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ (JICA) ប្រចាំកម្ពុជា បានសម្តែងនូវទឹកចិត្តរីករាយចំពោះការបំពេញបេសកកម្មការងារ រយៈពេលជាង ពីរឆ្នាំ ដោយទទួលបាននូវកិច្ចសហប្រតិបត្តិការដ៏ល្អ ជាមួយស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ។ ក្នុងនោះ ជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺស្ថិតក្នុងកិច្ចសហការយ៉ាងល្អប្រសើរ ជាពិសេសគម្រោងអភិវឌ្ឍន៍ទឹកស្អាត និង គោលនយោបាយលើកទឹកចិត្តវិស័យសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ។ ដោយឡែក លោក **Adachi Itsu** ប្រធានតំណាងថ្មីនៃអង្គការ JICA ក៏បានបង្ហាញនូវជំហរសហការគាំទ្រ ដើម្បីឱ្យការអនុវត្តគម្រោងនានា ជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្មសម្រេចបានជោគជ័យ ។ ក្នុងនោះវិស័យទឹកស្អាត ជាគម្រោងដែលអង្គការ JICA មានការប្តេជ្ញាចិត្តខ្ពស់ ដើម្បីកម្ពុជាទទួលបានទឹកស្អាតប្រើប្រាស់សម្រាប់ទាំងអស់គ្នា ស្របតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកំពស់សុខមាលភាពប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ